01241493

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 05 / 2016
ម៉ោង (Time/Heure): 14:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E399/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំប្រើប្រាស់ចម្លើយមួយចំនួនពីមន្ទីរសន្តិសុខ ស-២១ អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុង

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយដែលបានដាក់នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦ ដោយមេធាវីការពារក្តី នួន ជា ដែលស្នើសុំការអនុញ្ញាតប្រើប្រាស់ចម្លើយពីមន្ទីរសន្តិសុខ ស-២១ របស់ កុយ ធួន, យឹម សម្បត្តិ និង ជា នន់ ដោយផ្អែកលើមូលដ្ឋានថា មានភស្តុតាងដើម្បីតតាំងទៅនឹងការសន្មត់អំពីហានិភ័យពិតប្រាកដដែលចម្លើយទាំងនេះអាចទទួលបានតាមរយៈការធ្វើទារុណកម្ម (ឯកសារ E399 កថាខណ្ឌ ១, ៣១-៣២)។ ជាជម្រើសម្យ៉ាងទៀត មេធាវីការពារក្តី នួន ជា ស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យអនុវត្តសិទ្ធិអំណាចរបស់ខ្លួនតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដើម្បីបើកការស៊ើបអង្កេតទៅលើកាលៈទេសៈនានាដែលចម្លើយទាំងនេះត្រូវបានរៀបចំឡើង មុនពេលសម្រេចទៅលើការប្រើប្រាស់ចម្លើយទាំងនេះដោយស្របច្បាប់ (ឯកសារ E399 កថាខណ្ឌ ៣០, ៣២)។ នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ចម្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា។ សហព្រះរាជអាជ្ញាជំទាស់ទៅនឹង

ការប្រើប្រាស់ចម្លើយទាំងនេះនៅក្នុងការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ លើកលែងតែថា (ក) ការប្រើប្រាស់ចម្លើយទាំងនោះមិនស្ថិតនៅក្រោមការហាមឃាត់ដោយមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងការប្រព្រឹត្តិមកលើខ្លួន ឬ ទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោក ("CAT") ឬ (ខ) ឯកសារទាំងនេះត្រូវបានប្រើក្នុងលក្ខខណ្ឌមានកម្រិតដែលបានអនុញ្ញាតដោយអង្គជំនុំជម្រះ (ឯកសារ E399/2 កថាខណ្ឌ ២, ៦, ៣០)។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ការស៊ើបអង្កេតបន្ថែមទៀតមិនមែនជាការចាំបាច់ និងពុំអាចអនុវត្តបានទេ (ឯកសារ E399/2 កថាខណ្ឌ ២)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំដល់អង្គជំនុំជម្រះឱ្យបដិសេធសំណើសុំរបស់មេធាវីការពារក្តី នួន ជា (ឯកសារ E399/1 កថាខណ្ឌ ២៤)។ នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យមេធាវីការពារក្តី នួន ជា ដាក់សារណាតបរួមជាភាសាអង់គ្លេសសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ ដោយកម្រិតត្រឹម ២០ ទំព័រ ត្រឹមថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ (សូមមើលសារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦)។ នៅក្នុងសារណាតបរបស់ខ្លួន មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះច្រានចោលទឡ្ហីករណ៍នានាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងចម្លើយតបរបស់ពួកគេ និង ស្នើសុំឱ្យអនុញ្ញាតប្រើប្រាស់ចម្លើយពីមន្ទីរសន្តិសុខ ស-២១ របស់ កុយ ធួន, យ៉ឹម សម្បត្តិ និង ជា នន់ (ឯកសារ E399/3 កថាខណ្ឌ ១, ៥៨)។

២. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖

ក. <u>បដិសេធ</u>សំណើសុំអនុញ្ញាតប្រើប្រាស់ចម្លើយពីមន្ទីរសន្តិសុខ ស-២១ របស់ កុយ ធួន, យ៉ឹម សម្បត្តិ និង ជា នន់ លើកលែងតែនៅក្នុងកាលៈទេសៈមានកម្រិត ដែលត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម (ឯកសារ E350/8)។ និង

ខ. <u>បដិសេធ</u>សំណើសុំបើកការស៊ើបអង្កេតបន្ថែមអនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង។

៣. សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចនេះនឹងចេញក្នុងពេលវេលាសមស្របខាងមុខ។